# ប្រាសាទស្ទឹងខាងលិច

ប្រាសាទស្ទឹងខាងលិច មានទីតាំងស្ថិតនៅក្នុងវត្តស្ទឹង តាមបណ្តោយផ្លូវជាតិលេខ៥៧ ពីខេត្តបាត់ដំបងទៅខេត្តប៉ៃលិន ក្នុងភូមិស្ទឹងកើត ឃុំស្ទឹង ស្រុកបាណន់ ចម្ងាយប្រមាណជា២០ គីឡូម៉ែត្រប៉ែកខាងលិចក្រុងបាត់ដំបង និងប្រមាណជា៦០ គីឡូម៉ែត្រពីទីរួមខេត្តប៉ៃលិន។ អំពីឈ្មោះនៃប្រាសាទនេះយើងពុំដឹងថាកើតឡើងតាំងពីពេលណាមកនោះទេ ឯឈ្មោះដើមនៃប្រាសាទនេះក៏ពុំដឹងដូចគ្នា ដ្បិតប្រាសាទពុំមានបន្សល់ជាសិលាចារឹកនោះទេ។ ប្រាសាទនេះមានការសិក្សាស្រាវជ្រាវតាំងពីដើមសតវត្សរ៍ទី២០ មកម្ល៉េះដោយលោក Etienne Aymonier និង Lunet de Lajonquière ជាដើម។ ឆ្នាំ១៩១១ លោក Lunet de Lajonquière បានចុះបញ្ជីប្រាសាទនេះលេខរៀងទី៨៦៧ ក្នុងសៀវភៅបញ្ជីបុរាណរបស់លោក។[៦]

ប្រាសាទស្ទឹងខាងលិច ជាប្រាសាទទោល កសាងលើទីរាប ធ្វើអំពីថ្មភក់ពណ៌លឿង មានប្លង់រាងបួនជ្រុងស្មើ បែរមុខទៅទិសឯកើត ភ្ជាប់ជាមួយសំណង់លយខាងមុខ (Ardha Mandapa) ហើយមានស្រះទឹកមួយនៅឯទិសអាគ្នេយ៍នៃប្រាសាទ (រូបលេខ១-២)។ សព្វថ្ងៃយើងពុំអាចចូលក្នុងប្រាសាទនេះបានទេ ដ្បិតផ្នែកខាងលើនៃប្រាសាទបាក់ធ្លាក់ចូលខាងក្នុង និងបរិវេណជុំវិញប្រាសាទ ប៉ុន្តែអ្នកស្រុកនៅតំបន់ក្បែរនេះនៅតែមានការគោរពបូជាប្រាសាទនេះដូចប្រាសាទបុរាណឯទៀតដែរ។

ប្រាសាទនេះមានទ្វាចូលនៅខាងកើត និងអមដោយទ្វារបញ្ឆោតបីទៀតនៅទិសខាងលិច ខាងជើង និងខាងត្បូង។ បើសិក្សាទៅលើក្បាច់លម្អលើសំណង់ស្ថាបត្យកម្មនៃប្រាសាទនេះមានតែផ្តែរទ្វារប្រាសាទប៉ុណ្ណោះដែលមានការឆ្លាក់លម្អ ចំណែក ហោជាង សរសេពេជ្រ សរសេផ្អោប ទ្វារបញ្ឆោត ឥតមានការឆ្លាក់ជាក្បាច់លម្អអ្វីសោះឡើយ ម្ល៉ោះហើយយើងអាចសន្និដ្ឋានបានថាប្រាសាទនេះពុំទាន់សាងសង់រួចរាល់គ្រប់ជ្រុងជ្រោយនោះទេ។

ផ្តែរទ្វារនៅប្រាសាទស្ទឹងនេះមានបីសំខាន់ៗ នៅទិសខាងកើត ខាងត្បូង ខាងលិច ដោយមានការឆ្លាក់បង្ហាញពីរឿងទេពកថាព្រហ្មញ្ញសាសនាសំខាន់ផ្សេងៗគ្នា ប៉ុន្តែផ្តែរទ្វារខាងជើងនៃប្រាសាទនេះពុំមានឆ្លាក់លម្អជាក្បាច់ផ្សេងៗ ឬចម្លាក់ទេពកថាអ្វីនោះទេ។

[៦] Lunet De Lajonquière, E. E. 1911, 446-447.

អត្ថបទដោយ៖ លាក់ ស៊ីផាន់ណា

*ផ្តែរទ្វារខាងកើត៖ អំពីរឿងកូរសមុទ្រទឹកដោះយកទឹកអម្រឹត (រូបលេខ២៣)។ ផ្តែរនេះបង្ហាញពីពួកទេពចំនួន៦នាក់ឈរនៅខាងក្បាលរបស់នាគពាសុកី ឬវាសុកី ឯពួកអសោរចំនួន៦នាក់ឈរកាន់ខាងកន្ទុយ។ ចំពោះការតុបតែងលម្អរវាងទេព និងអសោរ គឺមានការខុសគ្នាត្រង់ចំណុចមួយចំនួនដូចជាមកុដ ក្រវិល ខ្សែក និងសំពត់ជាដើម។ ផ្នែកកណ្តាលនៃផ្តែរនេះមានសរសេត្រង់មួយ ជាភ្នំមន្ទរដោយមានសត្វអណ្តើកដ៏ធំមួយឈ្មោះកុម៌ ជាអវតារទីពីររបស់ព្រះនារាយណ៍ទ្រពីក្រោមភ្នំមន្ទរកុំឱ្យលិចចូលសមុទ្រ ឯនៅលើខ្នងអណ្តើកមានទេពស្រីមួយលេចចេញពាក់កណ្តាលខ្លួនគឺព្រះនាងលក្ស្មី (មហេសីរបស់ព្រះនារាយណ៍) ហើយម្ខាងទៀតប្រហែលជាសេះសួគ៌ដែលមានឈ្មោះ ឧច្ច័យស្វរ។ នៅចំណ្តាលនៃភ្នំមន្ទរគឺជាព្រះនារាយណ៍ព្រះហស្តបួន ហើយនៅលើកំពូលភ្នំមន្ទរមានទេពមួយអង្គពីលើ ដែលអាចជាទម្រង់មួយរបស់ព្រះនារាយណ៍ ឬព្រះឥន្ទ្រ។ ផ្នែកខាងលើនៃផ្តែរនេះបង្ហាញពីការចូលរួមរបស់ទេពផ្សេងចំនួន១០អង្គ តែយើងអាចសម្គាល់បានតែព្រះព្រហ្មមួយប៉ុណ្ណោះដែរអង្គុយជាប់ភ្នំមន្ទរមានព្រហស្តបួន និងព្រះសិរបួន ហើយក៏មានឥសីចំនួនបីនាក់អង្គុយកាន់ផ្តាំដែរ។*

*ផ្តែរទ្វារខាងត្បូង៖ រឿងមហាភារត ត្រង់ឈុតការប្រកួតគ្នាលេងបាសកា (បាស្កា) រវាងមេក្រុមពួកបាណ្ឌព និងមេក្រុមពួកកោរព (រូបលេខ២៤)។ ផ្តែរទ្វារដ៏វិចិត្រនេះចែកជាពីរផ្នែកពោលនៅផ្នែកខាងក្រោមបង្ហាញពីទេពនិករ ឬអប្សរចំនួន៦នាក់អមសងខាងតោចំនួនបីដៃកំពុងទ្រពួកបាណ្ឌព និងពួកកោរព។[២] ឯផ្នែកខាងលើយើងអាចយល់សាច់រឿងនេះបានថាជាឈុតមួយក្នុងរឿងមហាភារតមុនមានសង្គ្រាមក្នុងកុរុក្សេត្រ គឺត្រង់ឈុតប្រកួតគ្នាលេងបាស្កា រវាងក្រុមពួកបាណ្ឌព នៅខាងឆ្វេងដែលមានបងទាំងប្រាំនាក់ដូចជា យុធិស្ធិរ ភីស្ម អជ៌ុន នកុល និងសហាទេវ ចំណែកខាងស្តាំវិញគឺជាក្រុមពួកកោរពដែលមានគ្នាដូចជា សកុនិ ទុយ៉ោធន និងទុស្សាសនៈ។ តាមរយៈសាច់រឿងគឺពួកបាណ្ឌពបានភ្នាល់ចាញ់អ្វីគ្រប់យ៉ាងទាំងអស់ដូចជាអស់នគរ អស់រាជ្យរួមទាំងនាងទ្រៅបទីជាមេហសីផង។ នៅខាងស្តាំដៃបង្អស់ផ្នែកលើនៃផ្តែរនេះគឺបង្ហាញពីឈុតមួយដែលទុស្សាសនៈចាប់សម្រាតសំពត់នាងទ្រៅបទី ក្រោយពេលយុធិស្ធិរចាញ់អ្វីៗគ្រប់យ៉ាង។*

*ផ្តែរទ្វារខាងលិច៖ អំពីរឿងព្រះនារាយណ៍ផ្ទុំរង់ចាំបង្កើតលោកថ្មី រឿងព្រះនារាយណ៍ត្រិវិក្រម និងចម្ងាក់បង្ហាញពីព្រះនារាយណ៍សម្លាប់ពួកអសោរ (រូបលេខ២៥)។ ផ្តែរទ្វារនេះមានលក្ខណៈពិសេសជាងផ្តែរទ្វារខាងកើត និងខាងត្បូង ដ្បិតសិល្បករបានឆ្លាក់រឿងសំខាន់ៗបីខុស*

[២] Roveda, V. 2005, 109.

គ្នាៗ។ អំពីព្រះនារាយណ៍ៈ នៅចំកណ្តាលនៃផ្តែរសិល្បករបានឆ្លាក់បង្ហាញរឿងព្រះនារាយណ៍ផ្ទំរង់ចាំបង្កើតលោកថ្មី ដោយបង្ហាញពីព្រះនារាយណ៍មានព្រះហស្តបួនកំពុងផ្ទំ និងមានមហេសីទាំងពីរអង្គរបស់ទ្រង់នៅចុងព្រះបាទ គឺព្រះនាងលក្ស្មី និងព្រះនាងភូមិ នៅពីលើខ្នងគជសីហ៍ ឬមករ (ម្ករ) ហើយមាននាគអនន្ត ឬនាគសេស នៅពីក្រោម។ ឯផ្នែកខាងលើមានព្រះព្រហ្ម ដែលផុសចេញពីព្រះកាយរបស់ព្រះនារាយណ៍ និងអមសងខាងដោយអសោរពីរនាក់គឺមធុ និងកៃដភ ដែលមានបំណងចង់លួចយកគម្ពីរពីព្រះព្រហ្ម។ ប្រការដែលគួរឱ្យកត់សម្គាល់ពីចម្លាក់នេះគឺគជសីហ៍ ឬមករដែលព្រះនារាណ៍ផ្ទុំលើនេះពុំឃើញមាននៅក្នុងសិល្បៈឥណ្ឌានោះទេ ប៉ុន្តែនៅក្នុងសិល្បៈខ្មែរ ពោលគឺនៅរវាងសតវត្សរ៍ទី១១ និងទី១២ ក្នុងរចនាបទបាភួន និងអង្គរវត្ត សិល្បករខ្មែរនិយមឆ្លាក់ទេវកថានេះខ្លាំងណាស់ដោយបង្ហាញព្រះនារាយណ៍ផ្ទំលើម្ករ ឬគជសីហ៍។[៣] ប៉ុន្តែលោក Etienne Aymonier យល់ថាសត្វដែលព្រះនារាយណ៍ផ្ទំលើនៅប្រាសាទស្ទឹងនេះគឺជារាជសីហ៍ទៅវិញ។[៤] ចំណែកឯផ្នែកខាងក្រោមជ្រុងខាងឆ្វេង គឺបង្ហាញពីឈុតក្នុងរឿងព្រះនារាយណ៍ត្រិវិក្រម ដែលជាទេពកថានិទានពីអវតារទីប្រាំរបស់ព្រះនារាយណ៍គឺវមន ឬមនុស្សតឿ សុំដីបីជំហានពីអសោរឈ្មោះពាលី។ ឯផ្នែកម្ខាងទៀតនៃផ្នែកនេះ ខ្ញុំពុំអាចមើលយល់ថាជារឿងទេពកថាអ្វីអោយប្រាកដនោះទេ ប៉ុន្តែបើមើលតាមចម្លាក់នេះប្រហែលជាចម្លាក់អំពីព្រះនារាយណ៍សម្លាប់ពួកអសោរ ដ្បិតចម្លាក់របៀបនេះក៏មាននៅតាមចម្លាក់មេទ្វារនៅប្រាសាទអង្គរវត្តផងដែរ។

សរុបជារួមមក បើទោះជាប្រាសាទស្ទឹងខាងលិចនេះពុំមានសិលាចារឹកដែលបញ្ជាក់ពីកាលបរិច្ឆេទរបស់ប្រាសាទយ៉ាងណាក៏ដោយ បើតាមរយៈការសិក្សាលើក្បាច់លម្អលើផ្តែរទ្វារទាំងបីរបស់ប្រាសាទ គេអាចសន្និដ្ឋានបានថា ប្រាសាទស្ទឹងខាងលិច កសាងនៅក្នុងស.វ.ទី១១ នៃគ.ស. ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី១ ឬព្រះបាទឧទ័យាទិត្យវរ្ម័នទី២ ក្នុងរចនាបថបាភួន។ ម្យ៉ាងទៀតតាមចម្លាក់រឿងទេពកថានៃផ្តែរទ្វារទាំងបី យើងអាចសន្និដ្ឋានបានថាប្រាសាទនេះទំនងជាឧទ្ទិស ឬតម្កល់ព្រះនារាយណ៍ ឬទេពសំខាន់ណាមួយក្នុងនិកាយវៃស្នវ។

[៣] ជី វដ្ឋា ២០០៧, ៦៧-៦៨ ; Mireille Bénisti 1965.

[៤] Aymonier, E. 1901; 291-292.

អត្ថបទដោយៈ លាក់ ស៊ីផាន់ណា

# ឯកសារពិគ្រោះ


ជី រដ្ឋា
២០០៧ ចម្លាក់ព្រះនរាយណ៍ផ្ទំនៅតាមប្រាសាទខ្មែរ,ព្រឹត្តិបត្រមហាវិទ្យាល័យបុរាណវិទ្យា, លេខទី១, ភ្នំពេញ

LUNET DE LAJONQUIÈRE, E. E.
1911 *Inventaire descriptif des monuments du Cambodge 3 1*. Paris, Leroux.

ROVEDA, V.
(2005). *Images of the gods: Khmer mythology in Cambodia, Thailand, and Laos*. Bangkok, Published and distributed in Thailand by River Books.

MIREILLE BÉNISTI.
(1965). Représentations khmères de Viṣṇu couché. Arts Asiatiques. PERSEE. http://www.persee.fr/web/revues/home/prescript/article/arasi_0004-3958_1965_num_11_1_917.

Aymonier, E.
(1901). *Le Cambodge*: II Paris: Ernest Leroux.



រូបលេខ១ ៖ ប្រាសាទស្ទឹងខាងលិច (មើលចំពីមុខ)



រូបលេខ២ ៖ ប្រាសាទស្ទឹងខាងលិច (មើលពីទិសពាយ័ព្យ)

អត្ថបទដោយ៖ លោក ស៊ីផាន់ណា



រូបលេខ២៣ ៖ ផ្តែរទ្វារខាងកើត៖ អំពីរឿងកូរសមុទ្រទឹកដោះយកទឹកអម្រឹត



រូបលេខ២៤ ៖ ផ្តែរទ្វារខាងត្បូង៖ រឿងមហាភារត ត្រង់ឈុតការប្រកួតគ្នាលេងបាសកា (បាស្កា)
រវាងមេក្រុមពួកបាណ្ឌព និងមេក្រុមពួកកៅរព



រូបលេខ២៥ ៖ ផ្តែរទ្វារខាងលិច ៖ អំពីរឿងព្រះនារាយណ៍ផ្ទុំរង់ចាំបង្កើតលោកថ្មី
រឿងព្រះនារាយណ៍ត្រិវិក្រម និងចម្លាក់បង្ហាញពីព្រះនារាយណ៍សម្លាប់ពួកអសោរ

អត្ថបទដោយ៖ លាក់ ស៊ីផាន់ណា